ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រពាំងសង្កែ រយៈពេល ៥ ឆ្នាំ (២០១៧-២០២២)

រៀបចំដោយរដ្ឋបាលជលផល ឧបត្ថម្ភដោយ FAO
ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧

ឈ្មោះសហគមន៍នេសាទ ៖ ត្រពាំងសង្កែ
ភូមិ ៖ ត្រពាំងសង្កែ កំពង់កែស និងត្រពាំងធំ
ឃុំ ៖ ត្រពាំងសង្កែ
ស្រុក ៖ ទឹកឈូ
ខេត្ត ៖ កំពត

# មាតិកា
## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

**១- ស្ថានភាពទូទៅ**

**២- អំពីប្រជាសាស្ត្រ**

ក- ប្រជាពលរដ្ឋ

ខ- មុខរបរ

**៣- កន្លែងនេសាទសហគមន៍និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**

ក- ទីតាំង

ខ- ដែននេសាទ

គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស

ឃ- ធនធានជលផល

**៤- ការធ្វើនេសាទ**

ក- អ្នកនេសាទ

ខ- ឧបករណ៍នេសាទ

គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ

**៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ**

ក- ទស្សនៈវិស័យ

ខ- គោលបំណង

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ

គ២- ផែនការកែលម្អកន្លែងនេសាទសហគមន៍

គ៣- ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស

គ៤- ផែនការគ្រប់គ្រងព្រៃលិចទឹក

គ៥- ផែនការទប់ស្កាត់បទល្មើសនេសាទ

គ៦- ផែនការប្រជុំប្រចាំខែនិងសម្ភារៈអនុវត្តការងាររបស់គណៈកម្មការសហគមន៍នេសាទ

គ៧- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

គ៨- ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ

គ៩- ផែនការបង្កើតកន្លែងទស្សនាកំសាន្តក្នុងសហគមន៍នេសាទ

គ១០-ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍

គ១១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ

គ១២- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ឃ. ផែនការយុទ្ធសាស្ត្រ

- តារាងកម្មវិធីការងារ

## ផែនការគ្រប់គ្រង
## កន្លែងនេសាទសហគមន៍

### ១ ស្ថានភាពទូទៅ

សហគមន៍នេសាទត្រពាំងសង្កែ បានធ្វើមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៩ ហើយបានរៀបចំបោះឆ្នោតឡើងវិញនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១០ ។

សហគមន៍នេសាទត្រពាំងសង្កែ មានទីតាំងស្ថិតនៅភូមិត្រពាំងសង្កែ កំពង់កែស និងត្រពាំងធំ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត។ ដែលមានសមាជិកសរុបចំនួន៧៣៤នាក់ ប្រុស៣៧១នាក់ ស្រី៣៦៣នាក់ ក្នុងនោះចំនួនគ្រួសារសរុបមានចំនួន៥០៧ គ្រួសារ។ មានគណៈកម្មការចំនួន០៩នាក់ ស្រី០៣នាក់។

កន្លងមកសហគមន៍នេសាទនេះ បានដំណើរការសកម្មភាពសំខាន់ៗ របស់ខ្លួនរួមមាន ៖

- បោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- រៀបចំបញ្ជីឈ្មោះសមាជិកនិងគណៈកម្មការសហគមន៍នេសាទ
- រៀបចំរចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទ
- រៀបចំលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- កំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍និងធ្វើផែនទី
- ចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ផ្សព្វផ្សាយច្បាប់ស្តីពីជលផល
- ទប់ស្កាត់បទល្មើសនេសាទក្នុងកន្លែងនេសាទសហគមន៍
- ការពារនិងដាំព្រៃលិចទឹក
- បង្កើតកន្លែងអភិរក្សជីវចំរុះនិងកន្លែងអភិរក្សព្រៃកោងកាង
- ការពារកន្លែងអភិរក្សជីវចំរុះនិងកន្លែងអភិរក្សព្រៃកោងកាង
- ចូលរួមវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានជលផល
- ទស្សនៈកិច្ចសិក្សា
- ចូលរួមប្រជុំជាមួយភូមិ ឃុំ ស្រុក
- បង្កើតក្រុមមុខរបរ (ដាំបន្លែ ក្រុមកែច្នៃផលនេសាទ ក្រុមសេវាទស្សនាកំសាន្ត)
- ប្រមូលព័ត៌មានទូទៅសំរាប់ធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

### ២ អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

ក. ប្រជាសាស្ត្រ

- ចំនួនប្រជាពលរដ្ឋសរុបក្នុងតំបន់មាន៥.៧៩២នាក់ ប្រុស២.៦៩០នាក់ ស្រី៣.១០២នាក់ ក្នុងនោះមានចំនួន១.០៦២គ្រួសារ ។ ប្រជាពលរដ្ឋក្នុងតំបន់ជាអ្នកកាន់សាសនាព្រះពុទ្ធ៧៥% កាន់សាសនាឥស្លាមចំនួន២៤% និងសាសនាកាតូលិក១%។

- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់ អ្នកមិនចេះអក្សរចំនួន៣៦នាក់ ស្រី២៣នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន៤១៨នាក់ ស្រី២០១នាក់ កម្រិតមធ្យមសិក្សាចំនួន២៦៤នាក់ ស្រី១៣២ និងកម្រិតឧត្តមសិក្សាចំនួន១៦នាក់ ស្រីចំនួន៧នាក់។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន២៩នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន៣នាក់ ស្រី១នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៧នាក់ ស្រី៤នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន២ នាក់ ស្រី១នាក់
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន៣នាក់ ស្រី២នាក់។

**ខ. មុខរបរ**

មុខរបរសំខាន់ៗ របស់សមាជិកក្នុងសហគមន៍នេសាទនេះរួមមាន៖

- ធ្វើនេសាទចំនួន២៥៦គ្រួសារ
- កែច្នៃផលនេសាទចំនួន២២គ្រួសារ
- ធ្វើស្រែចំនួន១៤៧ គ្រួសារ ទំហំ៧៤ហិកតា
- ធ្វើចំការចំនួន១៨គ្រួសារ ទំហំ៩ហិកតា
- ធ្វើវារីវប្បកម្មចំនួន១៦គ្រួសារ ស្រះចំនួន១០ស្រះ ទំហំ១៥មx១០មx២ម<br>បែចំនួន៦បែ ទំហំ២,៥មx៣មx១,៥ម
- ជាងផ្ទះចំនួន២គ្រួសារ
- លក់ដូរចំនួន៥១គ្រួសារ
- កម្មករ៨គ្រួសារ
- មន្ត្រីរាជការ១២គ្រួសារ
- ចិញ្ចឹមសត្វ៣៤គ្រួសារ ។
- ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំមានចំនួន ៧.២០០.០០០រៀល ។

## ៣ កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

**ក. ទីតាំង**

កន្លែងនេសាទសហគមន៍ត្រពាំងសង្កែ ជាដែននេសាទសមុទ្រ ស្ថិតក្នុងខេត្តកំពត មានទំហំ៣៣៧ ហិកតា និង មានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹងផ្លូវជាតិក្នុងឃុំត្រពាំងសង្កែនិងជាប់ឃុំត្រពាំងព្រីង
- ខាងត្បូងទល់នឹងសមុទ្រ
- ខាងកើតទល់នឹងសហគមន៍នេសាទកំពង់សាមគ្គី ឃុំអូរក្រសារ
- ខាងលិចទល់នឹងឃុំកំពង់សំរោងនិងឃុំដំុគ្រៀល ។

**ខ. ដែននេសាទ**

កន្លែងនេសាទសហគមន៍នេសាទត្រពាំងសង្កែ មានដែនមុទ្រចំនួន១ ព្រៃកចំនួន៣ព្រែក គឺ៖

| | | |
|---|---|---|
| ដែនសមុទ្រ | ទំហំ៣០១ហិកតា | ពេញមួយឆ្នាំ |
| ព្រែកក្បាលរមាស | ទំហំ៨.០០០មx៧០ម | ពេញមួយឆ្នាំ |
| ព្រែកកំពង់ត្នោត | ទំហំ៣.០០០មx២០ម | ពេញមួយឆ្នាំ |
| ព្រែកស្ពានខៀវ | ទំហំ២.០០០មx១៧ម | ពេញមួយឆ្នាំ |

ដីទំនាបលិចទឹកមានទំហំសរុប ៦៦ ហិកតា។

**គ. តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស**

ក្នុងផ្ទៃសមុទ្រកន្លែងនេសាទសហគមន៍ត្រពាំងសង្កែ ទំហំ ៣៦,៩ហិកតា ពេញមួយឆ្នាំ

**ឃ. ធនធានជលផល**

- ប្រភេទត្រី ៖

ត្រីបបែលខ្លែង បបែលអក បបែលសាច់អុជ បបែលស្ពាន់ បបែលត្រឡោត បបែលមាន់ បបែលយាន ព្រុយវែង ប៉េកា គូន គូនបារាំង កាម៉យ កាឡមពុក ឆែឡាន ឆែឡានងើយ ជន្លួញមាន់ ស្លឹកឫស្សី ក្រចកក្របី កាគីម ត្រចៀកដំរី ដូរអង្គរ ព្រុយវែង កញ្ចាក់ស្លា ក្រឡុកខុប បែកឆ្នាំង ចិនចាស់ស ចិនចាស់ខ្មៅ កាំគួច ព្រុយខ្មៅ កាជី កាជីអុច កាហាវ កូនគុំ ក្រឡុកប៉ូវ ឆែកាម ចោរខ្លួនមូល កាំគួចខៀវ កាំគួចខ្ទឹមបារាំង ចោរ កន្ទុយរឹង កាម៉ុងឬប្លាធូ កាំជ្រួចលឿង កាំគួចមាស ចាបខ្មៅ កាឡាំង កាឡាំងឆៃលៀប ផ្ទោង ត្បក ភ្នែកស ឆ្មួតលឿង សំឡីឬចេក ចាបអុចខ្មៅ អាចម៍ស្អុយ អាំងកីយក្រហម អាំងកីយអុចពីរ អាំងកីយអុចកន្ទុយ បោះត្រា ឆ្លង់ក្រហម ភ្នែកធំ ក្រហម ឆ្លង់មុខឈរ ឆ្លង់ប្រផេះ សខ្មៅ ក្រហមស្រកាធំ ក្រហមស្រកាទន់ ទឹកកែ កែកៅ កាតាំង សេកបុក កាតាំងឆ្នូត សេកខៀវ កាតាំងប្រផេះ សំបោហៀរ ព្រលូស តិ អង្រែ ចាបខ្មៅ ចាបស ក្តចិនអុចខ្មៅ កញ្ចាញ់ច្រាស ក្អុក ត្បុកកោងកាង កាវ ភ្នែកឡាន ត្រសក់ ផ្ទក់សមុទ្រ កុក ក្រាញ់សមុទ្រ ស្លឹកខ្នោ ឆ្លាម អោបទូក ចានក្រហម ច្រកូបបី មឹកដូង មឹកកណ្តុល មឹកបំពង់ មឹកស្នូក មឹកហ៊ុយសាយ មឹកខ្មោច មឹកស្នូក មឹកពីងពាង សេះសមុទ្រ បង្គារខ្លឹង បង្គារប៉ាវ៉ា បង្កងប៉ាក បង្កងកន្ទប និងបង្កង...។ល។

- ប្រភេទវារីសត្វ ៖

ផ្សោត អណ្តើក គន្ទាយ ក្រាស ល្មិត គ្រំឆ្អិត គ្រែងឈាមកង្ហារ គ្រែងស គ្រែងមាត់វៀច គ្រែងជំពុះទា ងាវភក់ គ្រំជី ងាវក្រឡាហូល ងាវឃ្លុយ ពស់ ក្តាមស្នូក ក្តាមដំបង ក្តាមដង្កៀបស ក្តាមផ្តលាន់ ក្តាមជ័រ ក្តាមអុចបី ក្តាមសេះ ក្តាមខ្លា ក្តាមថ្ម ក្តាមផលិត ប្រឡាំងកាស កាច អន្ទង់ ខ្យងក្រឡាព្រំ ខ្យងកោត ខ្យងប្រាក់ ខ្យងវៀច ខ្យងដូង កង្កែប កាំប្រម៉ា និងឈ្លើងសមុទ្រ... ។ល។

- **ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ៖**

ដើមត្រចៀកក្រាញ់ ប្រង់ ក្រចកនាង ក្បាញស ក្បាញ ក្បាញខ្មៅ បាសាក់ បាសាក់ក្រហម បាសាក់ខ្មៅ បាសាក់សឬរំផ្លោង ស្មែក្រហម ស្មែស ឈើជ័រ សេមាន់សមុទ្រ ក្រញឹបក្រហម ក្រញឹបស ចាក កោងកាងស្លឹកតូច កោងកាងស្លឹកធំ ក្រញឹបឈ្មោល អំពូថ្ម អំពូលក្រហម អំពារ ម្លូថ្វា វល្លិប្រេងសមុទ្រ វល្លិពោះត្រី វល្លិរេឬផ្តៅស្វា បាសឬកបាសសមុទ្រ វល្លិត្រកួនទឹកសមុទ្រ រំចេក ព្រះអន្លក់ ត្រចៀក ព្រីសសមុទ្រ អណ្តាតពោះ និងដើមពោធិ៍សមុទ្រ សារាយ ជ្រូកទឹក អាគីង កាឈៀវ...។ល។

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ ៖

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន៥១៣នាក់ ស្រី៧៦នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មាន
- ចំនួន២.០២៧ នាក់ ស្រី៣០៤នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៨៧២នាក់ ស្រី១៣១នាក់។

### ខ. ឧបករណ៍នេសាទ ៖

- ឧបករណ៍នេសាទនិងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងត្រីផ្សេងៗ | ម៉ែត្រ | ៣៧ | ៤០០ម/គ្រួសារ | ១៤.៨០០ម | ពេញមួយឆ្នាំ |
| លបក្តាម | គ្រឿង | ៥ | ៥០គ្រឿង/គ្រួសារ | ២៥០គ្រឿង | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ៥ | ១វង់/គ្រួសារ | ៥វង់ | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ៧ | ៣០០ផ្លែ/គ្រួសារ | ២.១០០ផ្លែ | ពេញមួយឆ្នាំ |
| សន្ទូចមឹក | ផ្លែ | ៣០ | ៦០ផ្លែ/គ្រួសារ | ១.៨០០ផ្លែ | ពេញមួយឆ្នាំ |
| សន្ទូចដង | ផ្លែ | ២៥ | ១ផ្លែ/គ្រួសារ | ២៥ផ្លែ | ពេញមួយឆ្នាំ |
| មងបង្គា | ម៉ែត្រ | ៦ | ៣០០ម៉ែត្រ/គ្រួសារ | ១.៨០០ម៉ែត្រ | ពេញមួយឆ្នាំ |
| ឈឹបរុញដៃ | គ្រឿង | ៤១៥ | ១គ្រឿង/គ្រួសារ | ៤១៥គ្រឿង | ពេញមួយឆ្នាំ |
| មងអួនអួស | ម៉ែត្រ | ៥ | ១២ម៉ែត្រ/គ្រួសារ | ៦០ម៉ែត្រ | ពេញមួយឆ្នាំ |
| ផ្ទុងផាង | វង់ | ២៥ | ២វង់/គ្រួសារ | ៥០វង់ | ពេញមួយឆ្នាំ |
| ឆ្នុះបង្គារ ស្ទូចាក់ | គ្រឿង | ៣១៤ | ១គ្រឿង/គ្រួសារ | ៣១៤គ្រឿង | ពេញមួយឆ្នាំ |
| រាវបង្គារ | នាក់ | ៩០ | ២នាក់/គ្រួសារ | ១៨០នាក់ | ពេញមួយឆ្នាំ |
| លូកក្តាម(ខ្វា) | គ្រឿង | ១៥០ | ១គ្រឿង/គ្រួសារ | ១៥០គ្រឿង | ពេញមួយឆ្នាំ |
| រាវគ្រែង | នាក់ | ៤៨ | ២នាក់/គ្រួសារ | ៩៦នាក់ | ពេញមួយឆ្នាំ |
| រើសសារ៉ាយ | នាក់ | ៧៨ | ២នាក់/គ្រួសារ | ១៥៦នាក់ | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៥៥គ្រឿង | ៣០០-១.០០០គីឡូក្រាម | ៦-២២សេះ |
| ទូកអុំ និងចែវ | ២៥គ្រឿង | ៥០-១០០គីឡូក្រាម | |

- ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍ នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងត្រីផ្សេងៗ | ម៉ែត្រ | ១០២ | ៤០០ម/គ្រួសារ | ៤០,៨០០ម | ពេញមួយឆ្នាំ |
| លបក្តាម | គ្រឿង | ១៣ | ៥០គ្រឿង/គ្រួសារ | ៦៥០គ្រឿង | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ១៤ | ១វង់/គ្រួសារ | ១៤វង់ | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ១៩ | ៣០០ផ្លែ/គ្រួសារ | ៥.៧០០ផ្លែ | ពេញមួយឆ្នាំ |
| សន្ទូចមឹក | ផ្លែ | ៨៣ | ៦០ផ្លែ/គ្រួសារ | ៤.៩៨០ផ្លែ | ពេញមួយឆ្នាំ |
| សន្ទូចដង | ផ្លែ | ៥៩ | ១ផ្លែ/គ្រួសារ | ៥៩ផ្លែ | ពេញមួយឆ្នាំ |
| មងបង្គា | ម៉ែត្រ | ១៧ | ៣០០ម៉ែត្រ/គ្រួសារ | ៥.១០០ម៉ែត្រ | ពេញមួយឆ្នាំ |
| ឈឺបរុញដៃ | គ្រឿង | ១.១៤៦ | ១គ្រឿង/គ្រួសារ | ១.១៤៦គ្រឿង | ពេញមួយឆ្នាំ |
| មងអួនអូស | ម៉ែត្រ | ១៤ | ១២ម៉ែត្រ/គ្រួសារ | ១៦៨ម៉ែត្រ | ពេញមួយឆ្នាំ |
| ផ្ទុងផាង | វង់ | ៥៩ | ២វង់/គ្រួសារ | ១១៨វង់ | ពេញមួយឆ្នាំ |
| ឆ្នុះបង្គារ ស្នរចាក់ | គ្រឿង | ៨៦៧ | ១គ្រឿង/គ្រួសារ | ៨៦៧គ្រឿង | ពេញមួយឆ្នាំ |
| រាវបង្គារ | នាក់ | ២៤៨ | ២នាក់/គ្រួសារ | ៤៩៦នាក់ | ពេញមួយឆ្នាំ |
| លូកក្តាម(ខ្វា) | គ្រឿង | ៤១៤ | ១គ្រឿង/គ្រួសារ | ៤១៤គ្រឿង | ពេញមួយឆ្នាំ |
| រាវគ្រែង | នាក់ | ១៣២ | ២នាក់/គ្រួសារ | ២៦៤នាក់ | ពេញមួយឆ្នាំ |
| រើសសាវ៉ាយ | នាក់ | ២១៥ | ២នាក់/គ្រួសារ | ៤៣០នាក់ | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៥៦គ្រឿង | ៤០០-៥០០គីឡូក្រាម | ៦,៥ សេះ |
| ទូកអ៊ុំ និងចែវ | ៧២គ្រឿង | ១០០-២០០គីឡូក្រាម | |

- ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងត្រីផ្សេងៗ | ម៉ែត្រ | ៤៣ | ៤០០ម/គ្រួសារ | ១៧,២០០ម | ពេញមួយឆ្នាំ |
| លបក្តាម | គ្រឿង | ៦ | ៥០គ្រឿង/គ្រួសារ | ៣០០គ្រឿង | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ៨ | ១វង់/គ្រួសារ | ៨វង់ | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ៩ | ៣០០ផ្លែ/គ្រួសារ | ២.៧០០ផ្លែ | ពេញមួយឆ្នាំ |
| សន្ទូចមឹក | ផ្លែ | ៣៨ | ៦០ផ្លែ/គ្រួសារ | ២.២៨០ផ្លែ | ពេញមួយឆ្នាំ |
| សន្ទូចដង | ផ្លែ | ២៥ | ១ផ្លែ/គ្រួសារ | ២៥ផ្លែ | ពេញមួយឆ្នាំ |
| មងបង្គា | ម៉ែត្រ | ៧ | ៣០០ម៉ែត្រ/គ្រួសារ | ២.១០០ម៉ែត្រ | ពេញមួយឆ្នាំ |
| ឈឺបរុញដៃ | គ្រឿង | ៤៩៣ | ១គ្រឿង/គ្រួសារ | ៤៩៣គ្រឿង | ពេញមួយឆ្នាំ |
| មងអួនអូស | ម៉ែត្រ | ៦ | ១២ម៉ែត្រ/គ្រួសារ | ៧២ម៉ែត្រ | ពេញមួយឆ្នាំ |

| | | | | | |
|---|---|---|---|---|---|
| ផ្លូងផាង | វង់ | ២៥ | ២វង់/គ្រួសារ | ៥០វង់ | ពេញមួយឆ្នាំ |
| ឆ្នុះបង្គារ ស្នូរចាក់ | គ្រឿង | ៣៧២ | ១គ្រឿង/គ្រួសារ | ៣៧២គ្រឿង | ពេញមួយឆ្នាំ |
| រាវបង្គារ | នាក់ | ១០៦ | ២នាក់/គ្រួសារ | ២១២នាក់ | ពេញមួយឆ្នាំ |
| លូកក្តាម(ខ្វា) | គ្រឿង | ១៧៨ | ១គ្រឿង/គ្រួសារ | ១៧៨គ្រឿង | ពេញមួយឆ្នាំ |
| រាវគ្រែង | នាក់ | ៥៦ | ២នាក់/គ្រួសារ | ១១២នាក់ | ពេញមួយឆ្នាំ |
| រើសសារ៉ាយ | នាក់ | ៩២ | ២នាក់/គ្រួសារ | ១៨៤នាក់ | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៦០គ្រឿង | ៤០០-១.០០០គីឡូក្រាម | ៦,៥-១០ សេះ |

គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជា គក) (គ្រួសារអ្នកនេសាទ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីចំរុះ | ៩៩៥គីឡូក្រាម | ៩៨៥គីឡូក្រាម | ១.៩៨០គីឡូក្រាម |
| គ្រែង | ២.៤៦៤គីឡូក្រាម | ២.៣៣៦គីឡូក្រាម | ៤.៨០០គីឡូក្រាម |
| ក្តាម | ៦៩គីឡូក្រាម | ៦៧គីឡូក្រាម | ១៣៦គីឡូក្រាម |
| មឹក | ៥៤៨គីឡូក្រាម | ៥៣២គីឡូក្រាម | ១.០៨០គីឡូក្រាម |
| បង្គា | ៦២គីឡូក្រាម | ៥៩គីឡូក្រាម | ១២១គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

ក. ទស្សនៈវិស័យ ៖

សហគមន៍នេសាទត្រពាំងសង្កែ មានទស្សនៈវិស័យចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

ខ. គោលបំណង ៖

- ចូលរួមគ្រប់គ្រងដែននេសាទសមុទ្រ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹក ក្នុងពេលទឹកជោនៃនាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍចម្រុះ ដោយមានការចូលរួមសមាជិកសហគមន៍
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរដែលជាសមាជិកសហគមន៍នេសាទ បានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ – | | | ផ្សេង |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន (ក្នុងពេលតែមួយ) | |
| ក្នុងផ្ទៃសមុទ្រទំហំ៣៣៧ហិកតារបស់សហគមន៍នេសាទត្រពាំងសង្កែ | ពេញមួយឆ្នាំ | មងត្រីផ្សេងៗ | ៣០០ម/គ្រួសារ | ៥០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | លបក្តាម | ៤០គ្រឿង/គ្រួសារ | ២០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | សំណាញ់ | ១វង់/គ្រួសារ | មិនកំណត់ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ១៥គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | សន្ទូចមឹក | ៥០ផ្លែ/គ្រួសារ | ៥០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | សន្ទូចដង | ១ផ្លែ/គ្រួសារ | មិនកំណត់ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | មងបង្គា | ២០០ម៉ែត្រ/គ្រួសារ | ១៧គ្រួសារ | សមាជិកសហគមន៍និងអ្នក |

| | | | | | |
|---|---|---|---|---|---|
| | | | | | មិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | ឈើបរុញដៃ | ១គ្រឿង/គ្រួសារ | ៣០០គ្រួសារ | សមាជិកសហគមន៍ និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | ឆ្នុះបង្ការស្នរចាក់ | ១គ្រឿង/គ្រួសារ | ៤៥០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | រាវបង្ការ | ២នាក់/គ្រួសារ | មិនកំណត់ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | លូកក្តាម(ខ្វា) | ១គ្រឿង/គ្រួសារ | មិនកំណត់ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | រាវគ្រែងដោយដៃ | ២នាក់/គ្រួសារ | មិនកំណត់ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | រើសសារ៉ាយដោយដៃ | ២នាក់/គ្រួសារ | មិនកំណត់ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| -ព្រែកក្បាលមាស<br>-ព្រែកកំពង់ត្នោត<br>-ព្រែកស្ពានខៀវ<br>(តាមព្រែកនីមួយៗ) | ពេញមួយឆ្នាំ | មងត្រីផ្សេងៗ | ១៤០ម/គ្រួសារ | ៥គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | លបក្តាម | ២០គ្រឿង/គ្រួសារ | ៥គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | សំណាញ់ | ១វង់/គ្រួសារ | មិនកំណត់ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | សន្ទូចរនង | ១០០ផ្លែ/គ្រួសារ | ៥គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | សន្ទូចដង | ១ផ្លែ/គ្រួសារ | មិនកំណត់ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | ឈើបរុញដៃ | ១គ្រឿង/គ្រួសារ | ៧គ្រួសារ | សមាជិកសហគមន៍ និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | ផ្លុងផាង | ១វង់/គ្រួសារ | ២៥គ្រួសារ | សមាជិកសហគមន៍ និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | ឆ្នុះបង្ការស្នរចាក់ | ១គ្រឿង/គ្រួសារ | ២០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | រាវបង្ការ | ២នាក់/គ្រួសារ | មិនកំណត់ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | លូកក្តាម(ខ្វា) | ១គ្រឿង/គ្រួសារ | មិនកំណត់ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |

## គ.២ ផែនការកែលម្អកន្លែងនេសាទសហគមន៍

ផែនការកែលម្អដែននេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលម្អ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម - បញ្ចប់ |
|---|---|---|---|---|---|
| កន្លែងនេសាទសហគមន៍ត្រពាំងសង្កែ | ៣៣៧ហិកតា | ៣៣៧ហិកតា | ស្វែងរកម្ចាស់ជំនួយ (ធ្វើគម្រោងស្នើសុំ) | ១០០ | ២០១៧ - ២០១៩ |
| | | | ប្រជុំផ្សព្វផ្សាយ | ២០០ | ២០១៧ - ២០១៩ |
| | | | កំណត់ទីតាំង | ៥០០ | ២០១៧ - ២០១៩ |
| | | | បោះបង្គោលព្រំបន្ថែមចំនួន២០បង្គោល | ៤.០០០ | ២០១៨ - ២០២១ |
| កន្លែងនេសាទសហគមន៍ | ពង្រីកបន្ថែម | ពង្រីកបន្ថែម | ស្វែងរកម្ចាស់ជំនួយ (ធ្វើគម្រោងស្នើសុំ) | ១០០ | ២០១៨ - ២០១៨ |
| | | | ប្រជុំផ្សព្វផ្សាយ | ១០០ | ២០១៨ - ២០១៨ |
| | | | កំណត់ពង្រីកកន្លែងនេសាទសហគមន៍ | ៥០០ | ២០១៨ - ២០១៨ |
| | | | រៀបចំផែនទីស្នើសុំសេចក្ដីសម្រេច | ៣០០ | ២០១៨ - ២០១៨ |
| | | | បោះបង្គោលព្រំបន្ថែមចំនួន១០បង្គោល | ១.៥០០ | ២០១៨ - ២០២១ |

## គ.៣ ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស ត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ(ហ.ត) ត្រូវអភិរក្ស | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| កន្លែងនេសាទសហគមន៍ត្រពាំងសង្កែ | ទំហំ ៣៦,៩ ហិកតា X=416964 Y=1165075 X=416196 Y=1164985 X=416305 Y=1165478 X=417133 Y=1165559 | -ត្រីមេពូជ -ស្មៅសមុទ្រ -សារ៉ាយសមុទ្រ | ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងការហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ (ប្ដូរលើក) | ១.២០០ | ២០១៧ | ២០១៨ |
| | | | បោះបង្គោលព្រំតំបន់អភិរក្ស បង្គោលស៊ីម៉ង់៤បង្គោល ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៨.០០០ | ២០១៧ | ២០១៨ |
| | | | យាមល្បាតការពារកន្លែងអភិរក្ស | ៣.៨០៨ | រយៈពេលប្រាំឆ្នាំ | |

## គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក (កោងកាង)

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំឡើងវិញដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទព្រៃឈើការពារ | សកម្មភាព | | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|---|
| កន្លែងនេសាទសហគមន៍ត្រពាំងសង្កែ | ៥៥ហិកតា | ព្រៃកោងកាង | ផ្សព្វផ្សាយពីកន្លែងព្រៃលិចទឹកឱ្យបានទូលំទូលាយ | បិទឯកសារ | ៦០ | ២០១៧ | ២០១៨ |
| | | | | ប្រជុំ | ៥៦២ | | |
| | | | បោះបង្គោលព្រំព្រៃកោងកាងចំនួន២០បង្គោលនិងសរសេរស្លាកសញ្ញា | | ៤០០ | ២០១៧ | ២០១៨ |
| | | | ដាំព្រៃកោងកាងចំនួន៥០.០០០ដើម | | ៣១.២៥០ | ២០១៧ | ២០២២ |
| | | | ថែរក្សា ការពារព្រៃកោងកាង | | ៦.២៥០ | ២០១៧ | ២០២២ |

## គ៥-ផែនការទប់ស្កាត់បទល្មើសជលផល

ផែនការចុះទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចខាងក្រោម:

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| -ប្រជុំផ្សព្វផ្សាយ ២ដង/ឆ្នាំ<br>-ផ្សព្វផ្សាយបិទឯកសារ២ដង/ឆ្នាំ<br>-ចែកផ្សព្វផ្សាយ២ដង/ឆ្នាំ | -មានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទ និងសារៈសំខាន់នៃធនធានជលផល<br>-មានការយល់ដឹងពីការគ្រប់គ្រងសហគមន៍នេសាទ<br>-ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ | ៤.០០០ | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល | មករានិងមិថុនា/រៀងរាល់ឆ្នាំ | |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រចាំត្រីមាស | -គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗ<br>-មានផែនការសមស្រប ជាក់លាក់ដើម្បីចុះអនុវត្តន៍ការងារ | ៣៣០ (៤ដង/ឆ្នាំ) | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ | មករា និងមិថុនា/រៀងរាល់ឆ្នាំ | |
| អនុវត្តផែនការ៖<br>(រៀបចំកំលាំងចុះ បង្ក្រាបដល់ទីកន្លែងដោយទំនាក់ទំនង និងសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធនិងអង្គការដៃគូ) | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកស.នធូរធារ | ៧.២០០ (២៤០/ដង) | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ | (៤ដង/ខែ)<br>(រយៈពេលប្រាំឆ្នាំ) | |
| មធ្យោបាយនិងសម្ភារៈ | មានលទ្ធភាពចុះល្បាតដោយ | ៣.៨១០ | គណៈកម្មការ | ២០១៧ | ២០២២ |

| | | | | | |
|---|---|---|---|---|---|
| -សាំងឬម៉ាស៊ុតនិងប្រេងបាត<br>-អាវភ្លៀង អាវពោង ពិល មួក<br>-កាតទូរស័ព្ទ អាយកូមទាក់ទង<br>-ម៉ាស៊ីនថត កែវយឹត | មានប្រសិទ្ធិភាព | | សមាជិកស.ន<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល<br>អង្គការដៃគូ | | |
| ទិញទូកស្ពាច់និងម៉ាស៊ីនថ្មី<br>ចំនួន១គ្រឿង | មានមធ្យោបាយចុះល្បាត | ២.៥០០ | គណៈកម្មការ<br>សមាជិកស.ន<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល<br>អង្គការដៃគូ | ២០១៧ | ២០១៨ |

គ៦-ផែនការប្រជុំប្រចាំខែនិងសម្ភារៈអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំគណៈកម្មការសហគមន៍នេសាទ សប្តាហ៍ទី៣នៃខែ/រៀងរាល់ខែ | -របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-មានផែនការណ៍អនុវត្តបន្ត | ៦៦០ | -គណៈកម្មការ<br>-ក្រុមល្បាត | ២០១៧ | ២០២២ |
| ប្រជុំជាមួយអាជ្ញាធរឃុំឬស្ថាប័នពាក់ព័ន្ធ(២២-២៨/រៀងរាល់ខែ) | -ទទួលព័ត៌មាននិងផ្តល់របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-បញ្ចូលផែនការណ៍ជាមួយផែនការអភិវឌ្ឍន៍ឃុំ/ស្ថាប័ន | ៩០០ | -អាជ្ញាធរឃុំ<br>-គណៈកម្មការ | ២០១៧ | ២០២២ |
| -សម្ភារៈការិយាល័យ<br>-ទិញក្រដាស់ ប៊ិច<br>-ព្រីនឯកសារ/កូបពីឯកសារ<br>-ការទំនាក់ទំនង | មានសម្ភារៈការិយាល័យសម្រាប់ប្រើប្រាស់ | ៥០០ | គណៈកម្មការ | រយៈពេល៥ឆ្នាំ | |

គ៧-ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល ត្រូវបានរៀបចំឡើងដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍នេសាទ ដូចមានខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការផ្សព្វផ្សាយ | | | | | |
| ប្រជុំផ្សព្វផ្សាយអំពីច្បាប់<br>-ជលផល ឯកសារគតិយុត្តិនានាដែលពាក់ព័ន្ធនឹងស.ន | -សមាជិកសហគមន៍នេសាទនិងអ្នកខាងក្រៅមានការយល់ដឹងនិងអនុវត្តតាម | ១.៥៨០ | គណៈកម្មការ,សមាជិកស.ននិងអ្នកក្រៅស.ន | មេសា-មិថុនា/រៀងរាល់ឆ្នាំ | |

| | | | | | |
|---|---|---|---|---|---|
| -លទ្ធផលកៈបទបញ្ជាផ្ទៃក្នុងស.ន ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍<br>-បរិស្ថាន<br>-ការចូលរួមជាសមាជិកសហគមន៍នេសាទ<br>-ភូមិ ឃុំ មានសុវត្ថិភាព<br>-អំពើហិង្សាក្នុងគ្រួសារ និង -បទពិសោធន៍ដែលទទួលបាន | -សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការ និងវិធានច្បាប់នានាដែលបានផ្សព្វផ្សាយ<br>-ផលត្រីនៅក្នុងសហគមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានច្រើននាំឲ្យជីវភាពធូរធារ<br>-ការរស់នៅមានសុវត្ថិភាព និងគ្មានអំពើក្នុងគ្រួសារ | | អាជ្ញាធរមូលដ្ឋាន ជំនាញជលផល, អង្គការដៃគូ | | |
| បិទផ្សាយឯកសារ ១ដង/ឆ្នាំ | | ១៦០ | | ខែមករា/ (រាល់ឆ្នាំ) | ខែមករា (រាល់ឆ្នាំ) |
| -ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍ដល់អ្នកនេសាទ១ដង/ឆ្នាំ<br>-ចែកចាយឯកសារនានាផ្សព្វផ្សាយដែលត្រូវ | | ៦០០ | | មិថុនា (រាល់ឆ្នាំ) | មិថុនា (រាល់ឆ្នាំ) |
| ផ្សព្វផ្សាយជ្រើសរើសក្រុមយុវជនសហគមន៍នេសាទគ្រពាំងសង្កែ | មានយុវជនចូលរួមក្នុងការងារគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ | ៦០០ | សមាជិកសហគមន៍នេសាទ | ២០១៧ | ២០២២ |
| ផែនការបណ្តុះបណ្តាល | | | | | |
| វគ្គបណ្តុះបណ្តាលពីរបៀបរៀបចំលិខិតរដ្ឋបាល :<br>-របាយការណ៍<br>-កំណត់ហេតុ<br>-គម្រោងស្នើសុំថវិកា<br>-គម្រោងថវិកានិងការគ្រប់គ្រងថវិកាស.ន | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តបាន ក្នុងការងារជាក់ស្តែង | ១.៤០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | ២០១៧ | ២០១៨ |
| វគ្គបណ្តុះបណ្តាលពីការប្រើប្រាស់កំព្យូទ័រ | គណៈសហគមន៍នេសាទ(៣នាក់) | ៣០៨ | គណៈកម្មការ ស.ន | ២០១៧ | ២០១៨ |
| វគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តន៍បាន ក្នុងការងារជាក់ស្តែង | ៤០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | ២០១៧ | ២០១៨ |
| វគ្គបណ្តុះបណ្តាលពីៈ<br>-ការគ្រប់គ្រងនិងសារៈសំខាន់នៃធនធានធម្មជាតិ | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង | ៥០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន | ២០១៨ | ២០១៩ |

| | | | | | |
|---|---|---|---|---|---|
| -សិទ្ធិជាមូលដ្ឋានលើធនធានធម្មជាតិ | និងអាចអនុវត្តបានក្នុងការងារជាក់ស្តែង | | សិស្ស,និស្សិត | | |
| វគ្គបណ្តុះបណ្តាលវិធីសាស្ត្រការប្រមូលព័ត៌មាន | គណៈកម្មការសហគមន៍នេសាទបានយល់ដឹងនិងអាចអនុវត្តបានក្នុងការងារជាក់ស្តែង | ៤០០ | គណៈកម្មការ ស.ន | ២០១៨ | ២០១៩ |
| វគ្គបណ្តុះបណ្តាលយេនឌ័រនិងការវិភាគយេនឌ័រ | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹងនិងអាចអនុវត្តបានក្នុងការងារជាក់ស្តែង | ៦០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | ២០១៨ | ២០១៩ |
| វគ្គបណ្តុះបណ្តាលពីការប្រែប្រួលអាកាសធាតុ | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹងនិងអាចអនុវត្តបានក្នុងការងារជាក់ស្តែង | ៥០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | ២០២០ | ២០២១ |
| វគ្គបណ្តុះបណ្តាលពីការសម្របសម្រួលដោះស្រាយទំនាស់ | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹងនិងអាចអនុវត្តបានក្នុងការងារជាក់ស្តែង | ៥០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | ២០២០ | ២០២១ |

### គ៨- ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ

ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការបណ្តុះបណ្តាល | | | | | |
| ចិញ្ចឹម (ត្រី ក្តាម បង្គារ) | មានមុខរបរបង្កើនប្រាក់ចំណូល | ១.៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៧ | ២០១៨ |
| ការរៀបចំវត្ថុអនុស្សាវរីយ៍ | មានមុខរបរបង្កើនប្រាក់ចំណូល | ១.០០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៧ | ២០១៨ |
| ចិញ្ចឹមសត្វ (មាន់ ទា ជ្រូក) | មានមុខរបរបង្កើនប្រាក់ចំណូល | ១.៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| កែច្នៃផលផលិតផលជលផល | មានមុខរបរបង្កើនប្រាក់ចំណូល | ១.៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| កែច្នៃសម្ភារៈប្រើប្រាស់ពីស្លឹកត្នោតស្លឹកចាក ផ្លែដូង | មានមុខរបរបង្កើនប្រាក់ចំណូល | ២.៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៩ | ២០២០ |

| | | | | | |
|---|---|---|---|---|---|
| និងសំបកខ្យង ក្រែង | | | | | |
| ផែនការបង្កើតក្រុមមុខរបរ | | | | | |
| ក្រុមចិញ្ចឹម ត្រី ក្តាម បង្គារ | -គណៈសហគមន៍និងសមាជិក នៃសាទបង្កើតឡើងជាក់ស្តែង<br>-មានបន្លែផ្គត់ផ្គង់ដល់តំបន់ទស្សនាក់សាន្ត និងទីផ្សារ<br>- មានមុខរបរបង្កើនប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៧ | ២០១៨ |
| ក្រុមរៀបចំលក់វត្ថុអនុស្សាវរីយ៍ | -មានការចូលរួមពីគណៈកម្មការនិងសមាជិកបង្កើតឡើងជាក់ស្តែង<br>-មានផលិតផលវត្ថុអនុស្សាវរីយ៍លក់ក្នុងតំបន់ទស្សនាក់សាន្តនិងទីផ្សារ<br>- មានមុខរបរបង្កើនប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៧ | ២០១៨ |
| ក្រុមកែច្នៃផលិតផលផលផល | គណៈសហគមន៍និងសមាជិក នៃសាទបង្កើតឡើងជាក់ស្តែង<br>-មានផលិតផលផលផលផ្គត់ផ្គង់ដល់តំបន់ទស្សនាក់សាន្តនិងទីផ្សារ<br>- មានមុខរបរបង្កើនប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ក្រុមចិញ្ចឹម មាន់ ទា ជ្រូក | -គណៈសហគមន៍និងសមាជិក នៃសាទបង្កើតឡើងជាក់ស្តែង<br>-មានបន្លែផ្គត់ផ្គង់ដល់តំបន់ទស្សនាក់សាន្ត និងទីផ្សារ<br>- មានមុខរបរបង្កើនប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ក្រុមកែច្នៃសម្ភារៈប្រើប្រាស់ពីស្លឹកត្នោត ស្លឹកចាក ផ្លែដូង និងសំបកខ្យង ក្រែង | គណៈសហគមន៍និងសមាជិក នៃសាទបង្កើតឡើងជាក់ស្តែង<br>-មានសម្ភារៈកែច្នៃផ្គត់ផ្គង់ដល់តំបន់ទស្សនាក់សាន្តនិងទីផ្សារ<br>-មានមុខរបរបង្កើនប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៩ | ២០២០ |

គ៩- ផែនការបង្កើតកន្លែងទស្សនាកំសាន្តក្នុងសហគមន៍នេសាទ

ផែនការបង្កើតកន្លែងទស្សនាកំសាន្តក្នុងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងនៅក្នុងកន្លែងនេសាទសហគមន៍ មានដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយដល់សមាជិកសហគមន៍នេសាទឱ្យបានទូលំទូលាយ | គណៈសហគមន៍នេសាទ សមាជិកស.ន បានយល់ដឹង និងអាចសម្រេចចិត្តក្នុងការចូលរួមក្នុងការងារជាក់ស្តែង | ៩០០ | -គណៈកម្មការ និងសមាជិកស.ន<br>-អាជ្ញាធរពាក់ព័ន្ធ<br>-ជំនាញជលផល | ២០១៧ | ២០២២ |
| រៀបចំទីតាំងទស្សនាកំសាន្ត<br>- ស្លាកសញ្ញាទីតាំងចំនួន៣<br>-សាងសង់រោងប្រជុំចំនួន១<br>-ផ្ទះស្នាក់នៅចំនួន៣០<br>-រោងលម្ហែចំនួន១០<br>-ទូកដឹកជញ្ជូនភ្ញៀវចំនួន១០<br>-ធុងសម្រាមចំនួន២៥<br>-បង្គន់អនាម័យ(ប្រុស/ស្ត្រី) -<br>-សាងសង់រោងលក់សំបុត្រ<br>-ផលិតសៀវភៅណែនាំ | ដំណើរការបង្កើតតំបន់ទស្សនាកំសាន្តទទួលបានជោគជ័យ | ១២.៥០០ | គណៈកម្មការ | ២០១៧ | ២០២២ |
| បង្កើតក្រុម – | -ក្រុមសេវាម្ហូបអាហារ<br>-ក្រុមរោងសម្រាកលម្ហែ<br>-ក្រុមផ្ទះស្នាក់នៅ<br>-ក្រុមអាវពោងហែលទឹក<br>-ក្រុមដឹកជញ្ជូន<br>-ក្រុមផ្ញើរយានយន្ត<br>-ក្រុមទោងលោតទឹក<br>-ក្រុមផ្គត់ផ្គង់ផលិតផលកសិកម្ម<br>-ក្រុមលក់ផលិតផលកែច្នៃនិងវត្ថុអនុស្សាវរីយ៍ | ១.២០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៧ | ២០២១ |
| រៀបចំហេដ្ឋារចនាសម្ព័ន្ធ៖<br>-ផ្លូវថ្នល់សម្រាប់យានយន្ត<br>-ស្ពានចូលព្រៃកោងកាង | -មានផ្លូវថ្នល់សម្រាប់យានយន្ត<br>-មានស្ពានចូលព្រៃកោងកាង<br>-មានរោងលក់សំបុត្រ | ២២៥.០០០ | គណៈកម្មការ និងសមាជិកស.ន | ២០១៧ | ២០២២ |
| ប្រជុំរៀបចំគោលការណ៍ផ្ទៃក្នុងរបស់ក្រុមមុខរបរ | មានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមនីមួយៗក្នុងការអនុវត្ត | ៨០០ | គណៈកម្មការ និងសមាជិកស.ន | ២០១៧ | ២០២១ |
| សន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យ | ធានាសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យក្នុងតំបន់ទស្សនាកំសាន្ត | ១២០ | គណៈកម្មការនិងសមាជិកស.ន | ២០១៧ | ២០២២ |

គ១០-ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍

ផែនការសម្រាប់អភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម :

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ប៉ាន់ស្មានតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ ប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រីតាមបៃ (៦គ្រួសារ) | ២បx២,៥មx៣មx១,៥ម | ត្រីឆ្តង់ | ២០០កូន/ឆ្នាំ | ៣០០ | ២០១៧ | ២០២១ |
| | ២បx២,៥មx៣មx១,៥ម | ត្រីផ្ទក់ | ២០០កូន/ឆ្នាំ | ២០០ | ២០១៧ | ២០២១ |
| | ២បx២,៥មx៣មx១,៥ម | ត្រីគុកកែ | ២០០កូន/ឆ្នាំ | ១.០០០ | ២០១៧ | ២០២១ |
| ចិញ្ចឹមត្រីតាមស្រះ (១០គ្រួសារ) | ១៥មx១០មx២ម | ទីឡាព្យា អណ្តែង | ១០.៥០០/ឆ្នាំ | ៨៤០ | ២០១៧ | ២០២១ |

គ១១- ផែនការសាងសង់ស្នាក់ការល្បាតសហគមន៍នេសាទ

ផែនការសាងសង់ស្នាក់ការល្បាតសហគមន៍នេសាទ ត្រូវបានរៀបចំនៅមាត់ពាមចំណុចកោះលលក ដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| សាងសង់ស្នាក់ការល្បាតសហគន៍នេសាទ ទំហំ៥មx៦ម ធ្វើពីគ្រឿងបេតុង ឆ្អឹងឈើ ប្រក់ហ្វីប្រូស៊ីម៉ង់ ដោយមានបង្គន់អនាម័យ | - សហគមន៍នេសាទមានស្នាក់ការល្បាតសម្រាប់ធ្វើការ -មានលទ្ធភាពពេញលេញក្នុងការការពារ គ្រប់គ្រង កន្លែងនេសាទសហគមន៍ | ៩.០០០ | គណៈកម្មការ សមាជិកស.ន ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | ២០១៧ | ២០១៩ |
| បណ្តាញអគ្គីសនី (ស៊ុលឡា) | មានថាមពលអគ្គីសនីសម្រាប់ស.នធ្វើការងារ | ៥០០ | | ២០១៧ | ២០១៩ |
| សម្ភារៈសហគមន៍នេសាទ (តុ ទូ ក្តារខៀន កៅអី កំព្យូទ័រ ព្រីនធើ និងស្កែនធើ) | មានសម្ភារៈសម្រាប់ស.នធ្វើការ | ១.១៥០ | | ២០១៧ | ២០១៩ |

គ១២-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម :

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំចាប់បញ្ចប់ | ចំណូលដុល្លា | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានសមាជិកភាពសហគមន៍នេសាទ | -ផ្សព្វផ្សាយការចូលជាសមាជិកនិងបង់ប្រាក់សមាជិកភាព<br>-ប្រមូលភាគទាន ១០០រៀល/ម្នាក់ | ២០១៧ | ២០២២ | ១៨,៣៥ | ១០០រៀល/នាក់ (៧៣៤នាក់) |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយជូនដំណឹងដល់សមាជិកបង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំសមាជិកស.ន ១.០០០ រៀល/ម្នាក់ | ២០១៧ | ២០២២ | ៩១៧,៥ | ១.០០០រៀល/ម្នាក់ (៧៣៤នាក់) |
| កម្រៃអ្នកនេសាទមិនមែនជាសមាជិកនិងអ្នកមកពីក្រៅ | ប្រមូលប្រាក់កម្រៃពី អ្នកនេសាទមិនមែនជាសមាជិកនិងអ្នកមកពីក្រៅ ៥.០០០រៀល/ទូក/១០ថ្ងៃ | | - | ១១.៤០៦ | អ្នកនេសាទមិនមែនជាសមាជិកបានបង់កម្រៃប៉ាន់ប្រមាណ ៥០ទូក/ថ្ងៃ |
| សរសេរគម្រោងស្នើសុំថវិកាពីៈ<br>-រាជរដ្ឋាភិបាល<br>-សប្បុរសជន<br>-អង្គការដៃគូរពាក់ព័ន្ធ | -ទំនាក់ទំនងជាមួយរដ្ឋាភិបាល និងអង្គការដៃគូរ<br>-សរសេរគម្រោងស្នើសុំថវិកា<br>-តាមដាន | | - | ៣៣៨.៣៦៦ | សរសេរគម្រោងស្នើសុំថវិកាចំណាយ ៥០០ដុល្លា |
| សរុប | | | | ៣៥០.៧០៨ | |

## ឃ. ផែនការយុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តន៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការ រួមមានសមាជិកគណៈកម្មការសហគមន៍នេសាទចាស់ទុំដែលមានបទពិសោធន៍និងចំណេះដឹងល្អៗ ជាពិសេសបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទង និងបច្ចេកទេសជលផល ដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែង អភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញពាក់ព័ន្ធ អង្គការនានា គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្របច្ចេកទេស និងថវិការសម្រាប់ដំណើរការអនុវត្តន៍ផែនការ
- រៀបចំផែនការ អនុវត្តន៍ផែនការតាមដំណាក់កាលនីមួយៗ ដោយជាក់លាក់និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផល និងស្ថាប័នពាក់ព័ន្ធ ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តន៍ផែនការ
- ធ្វើសមាហរណកម្មបញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំនិងផែនការស្ថាប័ននានា
- រៀបចំធ្វើស្នាក់ការល្បាតសហគមន៍នេសាទចំនួនមួយខ្នង និងទិញទូកម៉ាស៊ីនចំនួន១គ្រឿង សម្រាប់គ្រប់គ្រងនិងថែរក្សា ការពារកន្លែងនេសាទសហគមន៍ ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**ត្រពាំងសង្កែ** រយៈពេល ៥ ឆ្នាំ (២០១៧ ដល់ ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| គ១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ធ្វើនេសាទ | -មាននិរន្តរភាពធនធាន<br>-បង្កើនប្រាក់ចំណូល | | សមាជិកនិងគណៈកម្មការ | ២០១៧ | ២០២២ | |
| គ២.ផែនការកែលម្អកន្លែងនេសាទសហគមន៍ | -ស្វែងរកម្ចាស់ជំនួយ<br>-ប្រជុំផ្សព្វផ្សាយ/កំណត់ទីតាំង<br>-រៀបចំផែនទីស្នើសុំសេចក្ដីសម្រេច<br>-ពង្រីកកន្លែងនេសាទសហគមន៍<br>-បោះបង្គោលព្រំបន្ថែម | -មានការយល់ដឹងនិងឯកភាព<br>-កន្លែងនេសាទសហគមន៍មានទំហំធំជាងមុននិងមានប្រកាសទទួលស្គាល់<br>-មានបង្គោលព្រំច្បាស់លាស់ | ៧.៣០០ | - ស.ន.ត.ព.ស.ក<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៧ | ២០១៩ | |
| | | | | | ២០១៨ | ២០១៨ | |
| | | | | | ២០១៨ | ២០២១ | |
| គ៣.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | -ផ្សព្វផ្សាយឱ្យបានទូលំទូលាយ<br>-បោះបង្គោលនិងដាក់ស្លាកសញ្ញា | -មានត្រីមេពូជ<br>-ជីវចម្រុះកើនឡើងវិញ<br>-ព្រៃកោងកាងកើនឡើងវិញ | ១៣.០០៨ | - ស.ន.ត.ព.ស.ក<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ | ២០១៧ | ២០១៨ | |
| | យាមល្បាត ការពារ | | | | ២០១៧ | ២០២២ | |
| គ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | -ផ្សព្វផ្សាយឱ្យបានទូលំទូលាយ<br>-បោះបង្គោលព្រំព្រៃកោងកាង និងសរសេរស្លាកសញ្ញា | -ព្រៃកោងកាងបានគង់វង្ស<br>-ស្គាល់ច្បាស់ពីព្រំប្រទល់ព្រៃកោងកាង<br>-ជាជម្រកត្រី | ១.០២២ | - ស.ន.ត.ព.ស.ក<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៧ | ២០១៨ | |
| | -ដាំព្រៃកោងកាង<br>-ថែរក្សា ការពារ | | ៣៧.៥០០ | | ២០១៧ | ២០២២ | |
| គ៥.ផែនការទប់ស្កាត់បទល្មើសជលផល | -ប្រជុំផ្សព្វផ្សាយឱ្យបានទូលំទូលាយ<br>-ប្រជុំរៀបចំផែនការល្បាត<br>-អនុវត្តផែនការចុះបង្ក្រាបដល់ទីកន្លែង | -បទល្មើសជលផលថយចុះ<br>-ជីវចម្រុះនិងព្រៃលិចទឹកកើន<br>-ផលចាប់ត្រីបានច្រើន | ១៥.៤៤០ | - ស.ន.ត.ព.ស.ក<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ | ២០១៧ | ២០២២ | |
| | ទិញមធ្យោបាយនិងសម្ភារៈប្រើប្រាស់ | មានមធ្យោបាយ សម្ភារៈល្បាត | ២.៥០០ | | ២០១៧ | ២០១៨ | |
| គ៦.ផែនការប្រជុំប្រចាំខែនិងទិញសម្ភារៈអនុវត្តន៍ការងារគណៈកម្មការស.ន | -ប្រជុំ<br>,-ទិញសម្ភារៈការិយាល័យ | -របាយការណ៍លទ្ធផលសម្រេចបានប្រចាំខែ<br>-មានសម្ភារៈប្រើប្រាស់ | ២.០៦០ | - ស.ន.ត.ព.ស.ក<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ | ២០១៧ | ២០២២ | |
| គ៧.ផែនការផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល | ផ្សព្វផ្សាយ (ប្រជុំ បិទផ្សាយ ចែកឯកសារ)៖ ជលផល, ឯកសារគតិយុត្តិនានាដែលពាក់ព័ន្ធនឹងស.ន,ផែនការគ្រប់គ្រងស.ន,ការប្រែប្រួលអាកាសធាតុ,អំពើហឹង្សាក្នុងគ្រួសារនិងបទ | -គណៈកម្មការ សមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋមានការយល់ដឹង<br>-អាចយកទៅអនុវត្តន៍បាន | ២.៧៦០ | - ស.ន.ត.ព.ស.ក<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៧ | ២០២២ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ពិសោធន៍ដែលទទួលបាន | | | | | | |
| | បណ្តុះបណ្តាលស្តីពី ៖<br>-របាយការណ៍ កំណត់ហេតុ<br>-គម្រោងស្នើសុំនិងការគ្រប់គ្រងថវិកា<br>-ការប្រើប្រាស់កំព្យូទ័រ<br>-ភាពជាអ្នកដឹកនាំ | | ៤.៦០៨ | - ស.ន.ត.ព.ស.ក<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៧ | ២០១៨ | |
| | -ការគ្រប់គ្រងនិងសារៈសំខាន់នៃធនធានធម្មជាតិ<br>-សិទ្ធិជាមូលដ្ឋាននលើធនធានធម្មជាតិ<br>-វិធីសាស្ត្រការប្រមូលព័ត៌មាន<br>-យេនឌ័រនិងការវិភាគយេនឌ័រ | | | | ២០១៨ | ២០១៩ | |
| | -ការប្រែប្រួលអាកាសធាតុ<br>-សម្របសម្រួលដោះស្រាយទំនាស់ | | | | ២០២០ | ២០២១ | |
| គ៨.ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍ | បណ្តុះបណ្តាលស្តីពី៖<br>-ចិញ្ចឹម (ត្រី ក្តាម បង្គារ)<br>-រៀបចំវត្ថុអនុស្សាវរីយ៍ | -មានចំណេះដឹងនិងបច្ចេកទេសលើមុខរបរ<br>-អាចអនុវត្តន៍បានក្នុងការប្រកបមុខរបរ | ៨.០០០ | - ស.ន.ត.ព.ស.ក<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៧ | ២០១៨ | |
| | -ចិញ្ចឹមសត្វ (មាន់ ទា ជ្រូក)<br>-កែច្នៃផលផលិតផលជលផល | | | | ២០១៨ | ២០១៩ | |
| | កែច្នៃសម្ភារៈប្រើប្រាស់ពី៖ ស្លឹកត្នោត ស្លឹកចាក ផ្លែដូង សំបកខ្យង ក្រែង | | | | ២០១៩ | ២០២០ | |
| | បង្កើតក្រុមមុខរបរ៖<br>-ក្រុមចិញ្ចឹមត្រី ក្តាម បង្គារ និងសត្វ<br>-ក្រុមលក់វត្ថុអនុស្សាវរីយ៍<br>-កែច្នៃផលផលិតផលជលផល<br>-កែច្នៃស្លឹកត្នោត ស្លឹកចាក ផ្លែដូង សំបកខ្យង ក្រែង | -មានក្រុមមុខរបរកើតឡើង<br>-មានផលិតផលផ្គត់ផ្គង់ទីផ្សារ<br>-លើកស្ទួយកម្រិតជីវភាព | ២.៥០០ | - ស.ន.ត.ព.ស.ក<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៧ | ២០២០ | |
| គ៩.ផែនការបង្កើតកន្លែងទស្សនាកំសាន្ត | -ផ្សព្វផ្សាយឱ្យបានទូលំទូលាយ<br>-រៀបចំទីតាំងទស្សនាកំសាន្ត | -ប្រកពចំណូលដល់សហគមន៍នេសាទ | ២៤០.៥២០ | - ស.ន.ត.ព.ស.ក<br>- រាជរដ្ឋាភិបាល | ២០១៧ | ២០២២ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | -រៀបចំហេដ្ឋារចនាសម្ព័ន្ធផ្លូវ ស្ពានដើរ<br>-បង្កើតក្រុមមុខរបរ<br>-ប្រជុំរៀបចំគោលការណ៍ផ្ទៃក្នុងនៃក្រុម<br>-សន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យ | -បង្កើតមុខរបរដល់សមាជិកសហគមន៍នេសាទ<br>-មានភ្ញៀវមកកំសាន្ត | | - អង្គការដៃគូ<br>- សប្បុរសជន | | | |
| គ១០.ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ | -ចិញ្ចឹមត្រីតាមបែនិងស្រះ<br>-ទិញពូជ | -បង្កើតមុខរបរដល់សមាជិកសហគមន៍នេសាទ<br>-មានផលិតផលផ្គត់ផ្គង់ទីផ្សារ<br>-លើកស្ទួយកម្រិតជីវភាព | ២.៣៤០ | - ស.ន.ត.ព.ស.ក<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០២១ | |
| គ១១.ផែនការសាងសង់ស្នាក់ការល្បាតសហគមន៍នេសាទត្រពាំងសង្កែ | -សាងសង់ស្នាក់ការ<br>-រៀបចំបណ្តាញអគ្គីសនី(ស៊ុលឡា)<br>-ទិញសម្ភារៈ | -សហគមន៍នេសាទមានស្នាក់ការល្បាតធ្វើការ<br>-មានលទ្ធភាពពេញលេញក្នុងការការពារ គ្រប់គ្រងកន្លែងនេសាទសហគមន៍<br>-មានថាមពលអគ្គីសនីសម្រាប់ស.នធ្វើការងារ<br>-មានសម្ភារៈប្រើប្រាស់<br>-សម្រេចបានសកម្មភាពការងារ | ១០.៦៥០ | - ស.ន.ត.ព.ស.ក<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៧ | ២០១៩ | |
| គ១២.ផែនការថវិកាទ្រទ្រង់សហគមន៍នេសាទ | -ប្រមូលភាគទានសមាជិកភាព<br>- ភាគទានប្រចាំឆ្នាំ<br>- កម្រៃពីអ្នកខាងក្រៅ | មានថវិកាអនុវត្តន៍សកម្មភាពគ្រប់គ្រងសហគមន៍នេសាទ | ៣៥០.៧០៨ | - រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៧ | ២០២២ | |
| | សរសេរគម្រោងស្នើសុំរាជរដ្ឋាភិបាល សប្បុរសជន អង្គការដៃគូ | | | | ២០១៧ | ២០២១ | |

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៧ | | | ២០១៨ | | | ២០១៩ | | | ២០២០ | | | ២០២១ | | | ២០២២ | | |
| | មិថុនា | .... | ធ្នូ | មករា | .... | ធ្នូ | មករា | .... | ធ្នូ | មករា | .... | ធ្នូ | មករា | .... | ធ្នូ | មករា | ... | ឧស |
| គ១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | |
| គ២.ផែនការកែលម្អកន្លែងនេសាទសហគមន៍ | | | | | | | | | | | | | | | | | | |
| គ៣.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | | | | | | | |
| គ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | |
| គ៥.ផែនការទប់ស្កាត់បទល្មើសជលផល | | | | | | | | | | | | | | | | | | |
| គ៦.ផែនការប្រជុំប្រចាំខែនិងទិញសម្ភារៈការិយាល័យ | | | | | | | | | | | | | | | | | | |
| គ៧.ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល | | | | | | | | | | | | | | | | | | |
| គ៨.ផែនការបង្កើតមុខរបរសមាជិកសហគមន៍នេសាទ | | | | | | | | | | | | | | | | | | |
| គ៩.ផែនការបង្កើតកន្លែងទស្សនាកំសាន្តរបស់ស.ន | | | | | | | | | | | | | | | | | | |
| គ១០.ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងស.ន | | | | | | | | | | | | | | | | | | |
| គ១១.ផែនការសាងសង់ស្នាក់ការល្បាតរបស់ស.ន | | | | | | | | | | | | | | | | | | |
| គ១២.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | | | | | | | | | | | | | | | | | | |

សូមគោរពជូន
លោកមេឃុំត្រពាំងសង្កែ
"ដើម្បីជូនពិនិត្យនិងសម្រួល"
ត្រពាំងសង្កែ ថ្ងៃទី...០៤.......ខែ...០៤.......ឆ្នាំ២០១៧
ប្រធានគណៈកម្មការសហគមន៍នេសាទ
ត្រពាំងសង្កែ

ស៊ីម_ហ៊ុម

លេខ...០៣១.../...១៧...ខជស
បានឃើញនិងគោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផលក្បាលមាស
"ដើម្បីជូនពិនិត្យនិងសម្រួល"
ត្រពាំងសង្កែ ថ្ងៃទី...០៨...ខែ...០៣...ឆ្នាំ២០១៧
មេឃុំត្រពាំងសង្កែ

ឈុះ_សើ

បានឃើញនិងគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលព្រែកត្នោត
"ដើម្បីជូនពិនិត្យនិងសម្រួល"
...ស៊ាង... ថ្ងៃទី...០៩...ខែ...០៣...ឆ្នាំ២០១៧
នាយសង្កាត់រដ្ឋបាលជលផលក្បាលមាស

ឡុំ សុភាព

លេខ.០០៥..............
បានឃើញនិងគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកំពត
"ដើម្បីជូនពិនិត្យនិងសម្រួល"
ព្រែកត្នោត ថ្ងៃទី០៤.....ខែឧសភា.ឆ្នាំ២០១៧
នាយផ្នែករដ្ឋបាលជលផលព្រែកត្នោត

**អ៊ុក សំអុល**

លេខ.....០៤២..........
បានឃើញនិងគោរពជូន
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ខេត្តកំពត
"ដើម្បីជូនពិនិត្យនិងសម្រួល"
កំពត ថ្ងៃទី.០៤.....ខែ.ឧសភា.ឆ្នាំ២០១៧
នាយខណ្ឌរដ្ឋបាលជលផលកំពត

**ស.សុរិន**

លេខ.៣៤៩..........កស-កប
បានឃើញនិងគោរពជូន
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
"ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ"
កំពត ថ្ងៃទី.០៩.....ខែ.ឧសភា.ឆ្នាំ២០១៧
ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ខេត្តកំពត

**ចាន់ រិទ្ធិ**

លេខ.១៤៩៤.....ជផ
បានឃើញនិងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី២៣.. ខែ.មិថុនា.....ឆ្នាំ២០១៧
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**